SDGs | Journalism Reporting.

# ព្រឹត្តិប័ត្រព័ត៌មានទីមួយ - ខែមេសា ឆ្នាំ2021

## តើអ្វីជា “SDGsJR”?

“គោលដៅអភិវឌ្ឍន៍ប្រកបដោយចិរភាពក្នុងការរាយការណ៍ព័ត៌មាន (Sustainable Development Goals in Journalism Reporting)” គឺជាគម្រោងដែលមានរយៈពេល 36 ខែ ដែលត្រូវបានផ្តល់មូលនិធិរួមដោយ Erasmus+ ដែលជាកម្មវិធីរបស់ European Commission (គណៈកម្មការអឺរ៉ុប)។ វាត្រូវបានអនុវត្តដោយសម្ព័ន្ធនៃដៃគូចំនួនប្រាំបួន (9) ដែលមកពីប្រាំ (6) (sic) ប្រទេស៖ អេស្ប៉ាញ រ៉ូម៉ានី លុចសំបួ កម្ពុជា ចិន និង ម៉ាឡេស៊ី។ គោលបំណងរបស់គម្រោងគឺការកសាងសមត្ថភាពរបស់បុគ្គលិកអប់រំនៃស្ថាប័នអប់រំកម្រិតឧត្តម នៅក្នុងប្រទេសជាដៃគូនានា។ សកម្មភាពទាំងអស់នៃគម្រោងនេះផ្តោតសំខាន់លើគោលដៅក្នុងការអភិវឌ្ឍន៍កម្មវិធីសិក្សារយៈពេលវែងប្រកបដោយចិរភាពមួយ ក្នុងស្ថាប័នអប់រំកម្រិតឧត្តម(HEIs) ដែលមានភាពផ្សារភ្ជាប់ទៅនឹងទីផ្សារការងារ និង តម្រូវការសង្គម។

### តើគម្រោង “SDGsJR” មានគោលបំណងអ្វីខ្លះ?

ប្រព័ន្ធផ្សព្វផ្សាយមានសារៈសំខាន់ដូចនឹងអ្នកចូលរួមនិងអ្នកទទួលផលក្នុងដំណើរការនៃវឌ្ឍនភាពសង្គម។ ទោះយ៉ាងនេះក៏ដោយ កម្មវិធីសិក្សាសារគមនាគមន៍និងប្រព័ន្ធផ្សព្វផ្សាយនៅក្នុង គ្រឹះស្ថានអប់រំកំរិតឧត្តមសិក្សានៅអាស៊ី ហាក់ដូចជាមិនទាន់សមស្របសម្រាប់ការធ្វើការរាយការណ៍ប្រកបដោយចិរភាពនៅឡើយទេ។ ដូច្នេះ វគ្គសិក្សាថ្មីនឹងផ្តោតលើការអភិវឌ្ឍន៍ប្រកបដោយចិរភាព ក្នុងវិស័យសារព័ត៌មាននិងការរាយការណ៍ ដើម្បីបំពេញតាមកម្មវិធីសិក្សាបែបទំនើប ព្រមទាំងគោរពតាមតម្រូវការប្រព័ន្ធផ្សព្វផ្សាយ ដែលសេរីនិងមានភាពចម្រុះ។

ដោយសារតែហេតុផលទាំងនេះ គម្រោងមានបំណងចង់៖

- ពង្រឹងគុណភាពការអប់រំកម្រិតឧត្តម នៅក្នុងផ្នែកការរាយការណ៍ព័ត៌មានដោយដោះស្រាយបញ្ហាប្រឈមនានា។
- ដោះស្រាយបញ្ហាប្រឈមពីការប្រែប្រួលតម្រូវការនៃទីផ្សារការងារ និងផ្នែកសារព័ត៌មាន ឬការវិភាគនៃបញ្ហាទាំងនេះប្រកបដោយការអប់រំដែលមានគុណភាពប្រសើរជាងមុន និងសញ្ញាបត្រសម្រាប់ការជ្រើសរើស និងការរក្សាបេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។
- ណែនាំវិធីសាស្ត្របណ្តុះបណ្តាល និងការបង្រៀនថ្មីៗដើម្បីពង្រីកជំនាញ និងសមត្ថភាពរបស់អ្នកសារព័ត៌មាន នៅក្នុងមហាវិទ្យាល័យ។

Co-funded by the Erasmus+ Programme of the European Union

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

SDGs Journalism Reporting.

- បញ្ចូលគំនិតថ្មីៗក្នុងការរាយការណ៍ក្នុងប្រព័ន្ធផ្សព្វផ្សាយស្តីពី SDG និង ការសិក្សាលើបញ្ហាចម្បងក្នុងស្រុកដោយផ្អែកលើ ICT។
- គាំទ្រការអភិវឌ្ឍន៍កម្មវិធីសិក្សាដែលនាំយកមកពី EU ក្នុងផ្នែកសារព័ត៌មាន និងការរាយការណ៍ព័ត៌មានក្នុងកម្រិតថ្នាក់ជាតិ។
- បង្កើនទំនាក់ទំនងក្នុងចំណោមអ្នកសារព័ត៌មាន មន្ត្រី អ្នកតស៊ូមតិ ភាគីពាក់ព័ន្ធ និងប្រជាពលរដ្ឋ ដោយការលើកទឹកចិត្តឱ្យមានទំនាក់ទំនងរវាងសាកលវិទ្យាល័យនិងបុគ្គលទាំងនេះតាមរយៈវេទិកាឌីជីថលដោយបើកចំហរមួយ។

**តើមានអ្វីបានកើតឡើងខ្លះហើយមកដល់ត្រឹមពេលនេះ?**សកម្មភាពរបស់គម្រោងបានចាប់ផ្តើមដោយកិច្ចប្រជុំជាមួយដៃគូសហការ នៅ University of Santiago de Compostela ប្រទេសអេស្ប៉ាញ នាថ្ងៃទី17-18 ខែកុម្ភៈ ឆ្នាំ2020។ ដៃគូនីមួយៗធ្វើការបង្ហាញពីស្ថាប័នរបស់ខ្លួន ហើយការពិភាក្សាតុមូលអំពីតម្រូវការ និងបញ្ហាដែលអាចកើតមាន ដែលដៃគូនៃប្រទេសក្នុងតំបន់អាស៊ីបានប្រឈម ត្រូវបានលើកឡើង។ ក្រុមការងារបានយល់ស្របលើយុទ្ធសាស្ត្រតម្រង់ទិសនៃគម្រោង “SDGsJR” ហើយបានយល់ស្របថាលទ្ធផលរបស់គម្រោងគួរតែជា ថ្នាក់កម្មវិធីសិក្សា/ម៉ូឌុល(modules)នៃការរាយការណ៍សារព័ត៌មានលើ SDG ដែលនឹងត្រូវដាក់បញ្ចូលទៅក្នុងថ្នាក់ជំនាញសិក្សា(degree) ដែលមានស្រាប់នៅក្នុងស្ថាប័នអប់រំនីមួយៗ ដែលអាស្រ័យលើដំណើរការ នៃការទទួលស្គាល់គុណភាពនៅកម្រិតស្ថាប័នអប់រំ និង/ឬ កម្រិតថ្នាក់ជាតិតាមតម្រូវការ។





Co-funded by the Erasmus+ Programme of the European Union

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

សូមចូលទៅកាន់គេហទំព័ររបស់យើង៖ www.journalism-reporting.eu

ជួបជាមួយក្រុមការងារ “SDGsJR”

Co-funded by the Erasmus+ Programme of the European Union

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.